


# សម្លេងទុគ្គតជន-Voice of the Poor

## ព្រឹត្តប័ត្រពត៌មាន ABiC–ABiC Newsletter

លេខ ០០៥ កុម្ភៈ ២០០៥ — ឆ្នាំទី២ / No. 005 February 2005 – Year 2

ឧបត្ថម្ភដោយ/supported by USAID តាមរយៈ/through ARD Inc.


| បញ្ជីអត្ថបទ | ទំព័រ |
|---|---|
| ១. ការបន្តទន្ទ្រានដីព្រៃធ្វើជាកម្មសិទ្ធិ (Clearing of Forest for Land Acquisition Continued, p. 1) | … ១ |
| ២. ការកាប់ទន្ទ្រានដីនៅឃុំពីធ្នូ ស្រុកស្នួល (Land Clearing in Pithnou Commune of Snuol District, p. 3) | … ៣ |

## ការបន្តទន្ទ្រានដីព្រៃធ្វើជាកម្មសិទ្ធិ

បច្ចុប្បន្ននេះ ការកាប់ទន្ទ្រានដីព្រៃឈើដើម្បីយកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនពីសំណាក់អ្នកមានឥទ្ធិពល, អ្នកមានលុយ និង អ្នកមានអំណាចនៅតែបន្តមិនឈប់ឈរ និង កាន់តែធ្វើអោយមានភាពច្របូកច្របល់សម្រាប់ប្រជាពលរដ្ឋ និង អាជ្ញាធរមូលដ្ឋានតូចតាច ក៏ដូចជាការបាត់បង់ព្រៃឈើ និងការប៉ះពាល់ដល់តំបន់អភិរក្សជាច្រើនកន្លែង ។

ជាច្រើនខែកន្លងមកនេះមានការកាប់បំផ្លាញព្រៃឈើដែលស្ថិតនៅក្នុងឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ត្រូវបានប្រព្រឹត្តិឡើងដោយឈ្មោះ **អ.វ** ដែលប្រជាពលរដ្ឋបានអះអាងថាត្រូវជាក្មួយរបស់**សម្តេច ហ.ស.រ** ដែលមានតំណែងខ្ពស់នៅក្នុងស្ថាប័ននិតិបញ្ញាតិរបស់ជាតិ ។

ប្រជាជនមូលដ្ឋានទទួលបានលិខិតថតចម្លងផ្ទវការមួយ ដែលមានចុះហត្ថលេខាដោយ**សម្តេច ហ.ស.រ** ។ លិខិតនោះ បានចារបញ្ជូនទៅលោកមេឃុំឃ្សឹម ដោយស្នើសុំលោកមេឃុំអោយជួយសម្របសម្រួលដល់ក្មួយរបស់សម្តេចបានធ្វើកសិដ្ឋានចិញ្ចឹម គោ ក្របី និង ដាំដំណាំផ្សេងៗ ។ តែទោះជាយ៉ាងណាក្តីយើងមិនអាចសន្និដ្ឋានថា លិខិត និង ហត្ថលេខានោះពិតឡើយ ។

ទោះពិតឬមិនពិតក្តីបុគ្គល **អ.វ** បានទិញដីមួយចំនួនពីកសិករនៅក្នុងឃុំឃ្សឹម ហើយបានធ្វើការវាតពង្រីកផ្ទៃដីចូលទៅក្នុងតំបន់ព្រៃនៅជាប់នឹងដីដែលខ្លួនបានទិញពីប្រជាជននោះ តាមតែអំពើចិត្តដោយមានសំអាងទៅលើលិខិត និង ចំណារខាងលើនេះ ។ លោកប្រធានសង្កាត់រដ្ឋបាលព្រៃឈើប្រចាំឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ បានបញ្ជាក់ឱ្យដឹងថាដីព្រៃដែលបុគ្គល **អ.វ** កំពុងតែកាប់បំផ្លាញទាំងនោះគឺពិតជាដីព្រៃរបស់រដ្ឋ ប៉ុន្តែសមត្ថកិច្ចមូលដ្ឋានតូចតាចមិនដឹងថាត្រូវធ្វើយ៉ាងដូចម្តេច

ឡើយ បើមានចំណារពី **សម្តេច ហ.ស.រ** ដូច្នេះ ។

ប្រជាជនមូលដ្ឋានបានឱ្យដឹងថា រហូតមកដល់ពេលនេះ បុគ្គល **អ.វ** បានធ្វើការរានយកដីព្រៃទាំងអស់ប្រមាណជា២០ហិកតាទៅហើយ ។ បុគ្គលនេះមានគម្រោងរានយកដីព្រៃ រហូតដល់ទៅប្រមាណជា ១០០-២០០ហិកតា ដែលនឹងធ្វើអោយមានការបាត់បង់ ដីព្រៃមួយចំនួនធំ ហើយពិសេសទៅទៀតនោះ វាបានធ្វើ ឱ្យមានផលអាក្រក់ដល់ប្រជាពលរដ្ឋ និង ជំរុញឱ្យមានការកាប់ទន្រ្ទានយកដីនៅទីនោះដូចលោក **អ.វ** ពីសំណាក់អ្នកមានប្រាក់ និង មានអំណាចដ៏ទៃទៀត ។

> **Clearing Forest for Land Acquisition Continued**
>
> In the last few months Mr. O.V believed to be a nephew of Samdech H.S.R has bought up pieces of land from poor community people in Khseum commune and has cleared nearby forest estate to acquire more land. In a letter to Khseum commune councilor Samdech H.S.R requested that the commune chief provide necessary facilitation to his nephew to get land for farming livestock and agricultural crops.
>
> With the authoritative letter Mr. O.V has cleared around 20 ha of land into the forest; and he is planning to acquire about 100-200 ha at the expense of the forest. This act further encourages the other rich and powerful people to follow suit.
>
> If this act is allowed to continue it means that the forestry and land laws are only created to be broken. A modern society in which the law is not practiced can be comparable to a barbarous society.

ប្រសិនបើគ្មានការទប់ស្កាត់ទេ ការធ្វើបែបនេះ ហាក់ដូចជាមានន័យថាច្បាប់ព្រៃឈើ និងច្បាប់ដីធ្លី គ្រាន់តែជា ឯកសារដែលគ្មានប្រយោជន៍តែប៉ុណ្ណោះ ឬ មានន័យម្យ៉ាងទៀតថាច្បាប់គ្រាន់តែត្រូវបានបង្កើតមកសម្រាប់តែជាការជាន់ឈ្លីលេងតែប៉ុណ្ណោះ ។ បើអ្នក បង្កើតច្បាប់មិនគោរពច្បាប់ តើធ្វើម្តេចអ្នកដែលមិនបង្កើតច្បាប់ទៅគោរពច្បាប់ ។ នៅក្នុងសង្គមគ្រួសារ មាតាបិតា ត្រូវធ្វើជាគម្រូឱ្យបុត្រធីតា និង ណែនាំបុត្រធីតារបស់ខ្លួនឱ្យប្រព្រឹត្តិទៅតាមគន្លងសុជីវធម៌ ។ រីឯនៅក្នុងសង្គមជាតិវិញ អ្នកដែលបង្កើតច្បាប់ និង អ្នកដែលជម្រុញការអនុវត្តន៍ច្បាប់ត្រូវតែប្រព្រឹត្តិតាមគន្លងនៃច្បាប់ដើម្បីធ្វើជាគម្រូឱ្យសង្គម និង អប់រំណែនាំ ឱ្យសង្គមប្រព្រឹត្តទៅតាមគន្លងនៃច្បាប់ ។ បើសង្គមមួយគ្មានច្បាប់ សង្គមមួយមិនអនុវត្តច្បាប់ អាចប្រៀបបានជាសង្គមបុព្វកាលដែលជាសង្គមនៃអនារ្យជន ។

## ការកាប់ទន្ទ្រានដីនៅក្នុងឃុំ២ធ្នូ ស្រុកស្នួល

ការកាប់រានព្រៃដើម្បីទន្ទ្រានយកដីទៅលក់បានរីករាលដាលយ៉ាងខ្លាំងនៅក្នុងស្រុកមួយចំនួន ដែលស្ថិតនៅជនបទដាច់ស្រយាលនាពេលបច្ចុប្បន្ននេះ ។ ទោះបីកន្លងមកអាជ្ញាធរខេត្តខ្លះបានដាក់ចេញនូវវិធានការដើម្បីទប់ស្កាត់ និង បង្ក្រាបយ៉ាងណាក៏ដោយ ក៏វិធានការទាំងនោះ ហាក់ដូចជាពុំសូវមានប្រសិទ្ធិភាពឡើយ ។

**Land Clearing in Pithnou Commune of Snuol District**

Forest clearing has been taking place almost uncontrollable in Pithnou commune of Snuol district. Among the land claimants are the 60-70 poor families from Kampong Cham, Kratie and Prey Veng provinces who have received material and financial supports from the rich and powerful who will expectedly claim the land from them later.

In the area of Pithnou commune along National Road 14 that borders with Keo Seyma district of Mondulkiri province the new settlers are busy clearing land in Snuol Wildlife Sanctuary without restriction. No-one cares about and enforces the law.

If this continues what is the meaning of having wildlife sanctuary and who will gain and suffer from this game since these poor are only working for the rich and powerful for a quick and short term survival. Land will change from hand to hand and the trend will continue. What will be the implications for the land/agrarian reform program and poverty reduction effort of the Royal Government of Cambodia?

ស្រុកស្នួលជាស្រុកមួយដែលមានសកម្មភាពកាប់ទន្ទ្រានយកដីយ៉ាងខ្លាំងក្លា ។ បើយើងធ្វើដំណើរតាមដងផ្លូវជាតិលេខ១៤ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឃុំ២ធ្នូ យើងនឹងសង្កេតឃើញមានការកាប់ និង ដុតបំផ្លាញព្រៃយ៉ាងខ្លាំងក្លាដើម្បីទន្ទ្រានយកដីមកធ្វើជាកម្មសិទ្ធិសំរាប់លក់ ។ ក្នុងចំណោមអ្នកដែលមកធ្វើសកម្មភាពអនាធិបតេយ្យទាំងនោះ គឺជាប្រជាជនប្រមាណជា ៦០-៧០ គ្រួសារដែលធ្វើដំណើរមកពីខេត្តកំពង់ចាម, ខេត្តក្រចេះ និង ខេត្តព្រៃវែង ហើយអ្នកទាំងនេះភាគច្រើន មានការគាំទ្រផ្នែកសំភារៈ និង ថវិកាពីសំណាក់អ្នកមានប្រាក់ និង អ្នកមានអំណាចមួយចំនួន ដែលមានបំណងចង់ច្បាមយកដីទាំងនោះមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ។

ចំណែកឯនៅក្នុងតំបន់ការពារដែនជំរកសត្វព្រៃស្នួលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ក៏កំពុងរងការគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដោយការកាប់រានដីព្រៃដើម្បីតាំងលំនៅថ្មី ។ បើយើងធ្វើដំណើរតាមបណ្តោយផ្លូវជាតិពីស្រុកស្នួលកឆ្ពោះទៅខេត្តមណ្ឌលគិរីនៅក្បែរព្រំប្រទល់ស្រុកកែវសីមា ខេត្តមណ្ឌលគិរី យើងនឹងឃើញមានប្រជាជនមួយចំនួនធំកំពុងកាប់ដុតព្រៃឈើយ៉ាងអណាធិបតេយ្យគួរឱ្យព្រួយបារម្ភបំផុត ។

បើសិនជាស្ថាប័នជំនាញ, ក្រសួងពាក់ព័ន្ធ និង អជ្ញាធរមូលដ្ឋានពុំធ្វើការទប់ស្កាត់ឱ្យទាន់ពេលវេលា និង ចាប់អ្នកដៃដល់ និង អ្នកនៅពីក្រោយខ្នងដែលមានលុយកាក់ និង មានអំណាចយកទៅតុលាការដើម្បីព្រមានទេនោះ បញ្ហានៃការបំផ្លាញព្រៃឈើនេះមិនអាចស្ងប់ស្ងាត់បានឡើយ ហើយក៏នឹងមានផលអាក្រក់ដល់ប្រជាជនទៀតផង ព្រោះថាសព្វថ្ងៃនេះប្រជាពលរដ្ឋគ្រាន់តែជាអ្នក ស៊ីឈ្នួលកាប់ព្រៃឱ្យគេដើម្បីយកលុយមកទិញអង្ករច្រកឆ្នាំងចិញ្ចឹមគ្រួសារតែប៉ុណ្ណោះ ។ តើទង្វើនេះនឹងមានផលវិបាកយ៉ាងណាដល់ដំណើការកែទម្រង់ដីធ្លីនិងកសិកម្ម និងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា?



